

**ឈ្មោះបេក្ខជន៖** Alexis Mercedes Rinck
**ឈ្មោះយុទ្ធនាការ៖** Alexis for Seattle
**គេហទំព័រយុទ្ធនាការ៖** alexisforseattle.com
**ទីតាំងទីក្រុង៖** 8
**លេខទូរស័ព្ទយុទ្ធនាការ៖** 206-705-9305

ដោយមានបទពិសោធន៍គាំទ្រសេវាកម្មមនុស្ស និងគោលការណ៍សុខភាពសាធារណៈ ដែលណែនាំផែនការការឆ្លើយតបការគ្មានផ្ទះសម្បែងក្នុងគ្រាអាសន្ន និងការរៀបចំគោលការណ៍សារពើពន្ធ និងថវិកានៅសាកលវិទ្យាល័យវ៉ាស៊ីនតោន (University of Washington) ខ្ញុំនឹងនាំយកអ្នកជំនាញដែលត្រូវការទៅក្រុមប្រឹក្សាក្រុង (City Council) ដើម្បីបង្កើនលំនៅដ្ឋានដែលតម្លៃសមរម្យ ដែលយើងត្រូវតែមាន សហគមន៍សុវត្ថិភាព ដែលយើងទាំងអស់សមនឹង ទទួលបានវិធានាការដើម្បីជួយប្រជាពលរដ្ឋមានវិបត្តិ និងការវិនិយោគសហគមន៍ដែលធ្វើឱ្យប្រសើរឡើងនូវសមធម៌ និងឱកាស។

ការប្តេជ្ញាចិត្តរបស់ខ្ញុំចំពោះសេវាកម្ម ដែលជាមូលដ្ឋានគ្រឹះនៃបទពិសោធន៍ផ្ទាល់ខ្លួនដែលចែករំលែកដោយមនុស្សជាច្រើននៅក្នុងទីក្រុងស៊ីតថល Seattle សព្វថ្ងៃនេះ។ ខ្ញុំកើតមកក្នុងគ្រួសារឪពុកម្តាយវ័យជំទង់តស៊ូ ហើយចិញ្ចឹមដោយជីដូនជីតារបស់ខ្ញុំ។ គ្រួសាររបស់ខ្ញុំបានដោះស្រាយដំណើរវដ្តដ៏ឃោរឃៅនៃការជាប់ឃុំ ការប្រើប្រាស់សារធាតុ ញៀន និងការគ្មានផ្ទះសម្បែង។ ខ្ញុំអរគុណដែលមានការគាំទ្រនៅក្នុងសហគមន៍របស់ខ្ញុំ ដែលបានផ្តល់ផ្លូវទៅរកភាពជោគជ័យដល់ខ្ញុំ ហើយខ្ញុំចង់ធានាថាយុវជនទាំងអស់នៅទីក្រុងស៊ីតថល Seattle មានឱកាសដូចគ្នា។

ខ្ញុំត្រៀមខ្លួនរួចជាស្រេចដើម្បីនាំយកទស្សនៈ និងចំណង់ចំណូលចិត្តដែលបានជូនដំណើរចំពោះលទ្ធផលរបស់ខ្ញុំទៅកាន់ក្រុមប្រឹក្សាក្រុង (City Council) ហើយជាការបញ្ចេញមតិយោបល់សម្រាប់ប្រជាពលរដ្ឋទាំងអស់នៃទីក្រុងស៊ីតថល Seattle។ យើងមានបញ្ហាប្រឈមជាបន្ទាន់ដែលទាមទារគំនិតថ្មីៗ ថាមពល និងភាពជាអ្នកដឹកនាំ។ ដោយមានប័ណ្ណទឹកប្រាក់ និងសន្លឹកឆ្នោតរបស់អ្នក ខ្ញុំនឹងបង្កើតកំណត់ត្រានៃការតស៊ូមតិ និងសកម្មភាពរបស់ខ្ញុំសម្រាប់ទីក្រុងតថល Seattle ដែលមានតម្លៃសមរម្យ ដែលស្វាគមន៍ និងដឹកនាំផ្លូវទៅកាន់អនាគតដ៏ល្អប្រសើរ។

*បេក្ខជននេះកំពុងចូលរួមក្នុងកម្មវិធីប័ណ្ណប្រជាធិបតេយ្យ (Democracy Voucher Program)។*

**Khmer**



**ឈ្មោះបេក្ខជន៖** Tariq Yusuf

**ឈ្មោះយុទ្ធនាការ៖** Tariq ចូលជាសមាជិកក្រុមប្រឹក្សា

**គេហទំព័រយុទ្ធនាការ៖** tariqforcouncil.org

**មុខតំណែងក្រុង៖** ៨

**លេខទូរស័ព្ទយុទ្ធនាការ៖** 206-395-9356

រឿងរបស់ខ្ញុំគឺជារឿង ទីក្រុងស៊ីអាថល។ ដោយបានកើតមកមានឪពុកជនជាតិឥណ្ឌូនេស៊ី និងម្ដាយជនជាតិអាមេរិក ខ្ញុំបានឃើញការផ្លាស់ប្ដូរ និងការរីកចម្រើននៃតំបន់ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ។ ឪពុកម្ដាយរបស់ខ្ញុំពឹងផ្អែកយ៉ាងខ្លាំងលើកម្មវិធីសង្គមដោយរដ្ឋបាល និងទីក្រុងសំខាន់ៗ ដូចជាអាជ្ញាធរលំនៅឋាន ស៊ីអាថល ជាដើម។ ពួកគេបានជួយយើងឱ្យរួចផុតពីភាពគ្មានផ្ទះសម្បែង និងកសាងអោយមានជីវិតជោគជ័យ។ ខ្ញុំក៏បានបញ្ចប់ការសិក្សារបស់ខ្ញុំនៅសកលវិទ្យាល័យ វ៉ាស៊ិងតោន បានដឹកនាំអាជីពជោគជ័យក្នុងឧស្សាហកម្មបច្ចេកវិទ្យា និងបានផ្ដើមកសាងគ្រួសាររបស់ខ្ញុំ។ ទោះបីជាមានការលំបាកយ៉ាងណាក៏ដោយ ឪពុកម្ដាយរបស់ខ្ញុំបានចិញ្ចឹមខ្ញុំអោយមានតម្លៃនៃការយល់ចិត្ត ការអាណិតអាសូរ និងយុត្តិធម៌។ តម្លៃដែលខ្ញុំសង្ឃឹមថានឹងនាំយកទៅក្រុមប្រឹក្សាក្រុង។

សុបិន្តអាមេរិចរបស់ខ្ញុំក៏អាចធ្វើទៅបាន ប៉ុន្តែការធ្វើដំណើរនោះកាន់តែពិបាកសម្រាប់គ្រួសារសព្វថ្ងៃនេះ។ សេវាកម្មសង្គមដែលធ្វើឱ្យរឿងរបស់ខ្ញុំអាចទទួលបានគឺមិនអាចចូលប្រើបានទៀតទេ។ ខ្ញុំចង់ផ្លាស់ប្ដូរបញ្ហានោះ។

រដ្ឋាភិបាលទីក្រុងដើរតួយ៉ាងសំខាន់ក្នុងជីវិតរបស់យើង ក្នុងនាមជាសមាជិកក្រុមប្រឹក្សាក្រុង ខ្ញុំមានគម្រោងតស៊ូមតិសម្រាប់មនុស្សដូចជាឪពុកម្ដាយរបស់ខ្ញុំ ដែលធ្លាប់ជួបប្រទះវិបត្តហិរញ្ញវត្ថុ បើដាច់ប្រាក់ខែ១ខែ ខែក្រោយនឹងគ្មានប្រាក់សម្រាប់បង់ថ្លៃផ្ទះ។ ខ្ញុំមានគម្រោងផ្ដល់ដល់ទីក្រុងនេះវិញដោយការតស៊ូមតិយ៉ាងម៉ឺងម៉ាត់ដើម្បីអោយមានសមភាព យុត្តិធម៌ និងក្ដីមេត្តា ជួយអ្នកងាយរងគ្រោះបំផុតក្នុងសង្គម និងប្ដេជ្ញាជួយមនុស្សគ្រប់ៗគ្នា ដើម្បីយើងអាចកសាងសហគមន៍ដែលមានសាមគ្គីភាព។

*បេក្ខជនរូបនេះ កំពុងតែចូលរួមក្នុងកម្មវិធីប័ណ្ណទឹកប្រាក់ប្រជាធិបតេយ្យ។*